section 2.8.qxp 21/12/2004 8:22 AM Page 1





# ២.៨ ការអប់រំក្នុងសង្គម

## ២.៨.១. ប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្ស

"ដោយសារសង្គ្រាមកើតចេញពីចិត្តរបស់មនុស្ស ដូចនេះ មានតែចាប់ផ្ដើមពីចិត្តរបស់មនុស្សទេ ដែលអាចស្ថាបនារបងការពារសន្តិភាពបាន។"

***អារម្ភកថានៃធម្មនុញ្ញរបស់អង្គការយូណេស្កូ ១៩៤៦***

ពាក្យស្លោកនេះត្រូវបានសរសេរក្រោយចប់សង្គ្រាមលោក ដែលបានបំផ្លិចបំផ្លាញមនុស្សអស់រយៈពេលយ៉ាងយូរ សំលាប់មនុស្សរាប់លាននាក់ និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធពិភពលោកយ៉ាងធ្ងន់ធ្ងរ។ អ្នកស្ថាបនាអង្គការ យូណេស្កូ បង្កើតអង្គការនេះឡើងក្នុងគោលបំណងធានាថា មនុស្សជាតិនឹងមិនបង្កើតសង្គ្រាមបែបបំផ្លិចបំផ្លាញដូចមុនទៀតទេ។

ក្នុងន័យនេះ តើអង្គការយូណេស្កូ និងប្រព័ន្ធអង្គការសហប្រជាជាតិអនុវត្តពាក្យស្លោកដ៏មានអត្ថន័យនេះបានដោយរបៀបណា? ជាចំណុចចាប់ផ្ដើមមួយ មនុស្សជឿជាក់ថា ប្រតិកម្មរបស់ពិភពលោកទោះតាមរយៈសកម្មភាពរបស់មនុស្សដោយឆ្លាតវាងវៃយ៉ាងណា ក៏ការចែករំលែកចំណេះដឹង និងព័ត៌មានអាចជួយបង្កបរិយាកាសយោគយល់គ្នារវាងមនុស្ស និងមនុស្ស ហើយឈានទៅបង្កើតសន្តិភាពសំរាប់មនុស្ស និងប្រជាជាតិទូទាំងពិភពលោក។ សំខាន់ជាងនេះទៀត មនុស្សមើលឃើញថា ការអប់រំជាកងកំលាំងប្រយុទ្ធជួរមុខដើម្បីធានាឲ្យមនុស្សសត្វនៅលើពិភពលោកទាំងអស់មានសន្តិភាព និងវិបុលភាពយូរអង្វែង។

ដើម្បីបកប្រែទ្រឹស្តី និងអត្ថន័យក្នុងពាក្យស្លោកនេះឲ្យទៅជាការពិត អង្គការយូណេស្កូទទួលយកកាតព្វកិច្ចមួយដើម្បីអភិវឌ្ឍប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្ស ដែលជាបញ្ហាឆ្លងវិស័យនៅក្នុងប្រព័ន្ធអប់រំ។ ថ្មីៗនេះ បញ្ញាវ័ន្ត និងអ្នកជំនាញអប់រំមួយក្រុមបានផ្ដល់អនុសាសន៍ (Refer: 2_8_Recommended.pdf from CD ROM) ថា មុខវិជ្ជាប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្សត្រូវបញ្ចូលទៅក្នុងប្រព័ន្ធអប់រំគ្រប់កំរិតទាំងអស់។ "ការអប់រំអំពីគុណធម៌ និងតម្លៃត្រូវបញ្ចូលទៅក្នុងសកម្មភាពអប់រំទាំងអស់។ ដូចនេះ វិធីសាស្ត្រ និងសកម្មភាពរៀន និងបង្រៀនអំពីគុណធម៌ និងតម្លៃត្រូវរៀបចំឲ្យមានជាស្រេចសំរាប់ប្រើប្រាស់។ វិធីសាស្ត្រ និងសកម្មភាពរៀន និងបង្រៀនថ្មីនេះត្រូវបញ្ចូលខ្លឹមសារទាក់ទងនឹងតម្លៃ គុណធម៌ ភាពអត់ឱន និងសាមគ្គីភាព សីលធម៌ពលរដ្ឋ តម្លៃ និងគុណធម៌ជាមនុស្ស។ បើបានធ្វើបែបនេះ ប្រជាពលរដ្ឋគ្រប់រូបនឹងមានសន្តិភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅក្នុងចិត្តជាមិនខាន។"

# ២.៨. ការអប់រំនៅក្នុងសង្គម

## ២.៨.១. ប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្ស



អ្នកមានវិជ្ជាជីវៈជាអ្នកអប់រំបានពិចារណា និងធ្វើអន្តរាគមន៍ជាច្រើនដើម្បីធានាថា មុខវិជ្ជាប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្សបានយល់ជ្រួតជ្រាបដល់សិស្សឲ្យបានច្រើននាក់ ទោះជាកំពុងរៀននៅបឋមសិក្សា មធ្យមសិក្សា ឬឧត្តមសិក្សាក៏ដោយ ។ ឧទាហរណ៍ វិទ្យាល័យមធ្យមបច្ចេកទេស Barefoot នៅឥណ្ឌាផ្តល់ការណែនាំមូលដ្ឋានដល់សិស្សរបស់ខ្លួនអំពីបញ្ហាសង្គម ។

អំពាវនាវសុំឲ្យក្រសួងអប់រំ និងគ្រូបង្រៀនបញ្ចូលមុខវិជ្ជាសិទ្ធិមនុស្ស ភាពអន់ឱន និងប្រជាធិបតេយ្យទៅក្នុងការសិក្សារៀនសូត្រប្រចាំថ្ងៃនៅតាមសាលា ។ យ៉ាងណាក៏ដោយ ជាដំបូងគ្រូចាំបាច់ត្រូវការចំណេះដឹងទទួលបានពីការបណ្តុះបណ្តាលស្តីពីវិធីបង្រៀនមុខវិជ្ជានេះជាមុនសិន ។ សៀវភៅសិស្ស និងឯកសារបង្រៀនផ្សេងទៀតត្រូវរៀបរៀងទុកជាស្រេច ទោះជាការបង្រៀនដោយប្រើបច្ចេកវិទ្យាទំនើប ដូចជា អ៊ិនធឺណិត និងប្រព័ន្ធសំលេងផ្សេងទៀតស្ថិតនៅឆ្ងាយពីការពិតក៏ដោយ។ ការបោះពុម្ពផ្សាយសេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្សឲ្យបានច្រើនភាសាគឺជាមធ្យោបាយមួយទៀតក្នុងការផ្សព្វផ្សាយអំពីបញ្ហានេះ ។

# ២.៨ ការអប់រំក្នុងសង្គម

## ២.៨.១. ប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្ស

ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ សង្គ្រាម និងជំលោះនៅតែបន្តធ្វើឲ្យមានសភាពការណ៍រីករាលដែល ។ ប៉ុន្តែកម្មវិធីជាច្រើនត្រូវបានរៀបចំដំណើរការនៅក្នុងតំបន់ដែលមាន និងធ្លាប់មានជំលោះ និងកំពុងទទួលបានជោគជ័យ (ឯកសារយោង : Refer: 2_8_programmes.htm from CD ROM)។

ការសិក្សាអំពីស្ថានភាពនៅក្នុងប្រទេសមានប្រយោជន៏ខ្លាំងណាស់សំរាប់អ្នកសារព័ត៌មាន។ តើសិទ្ធិមនុស្សត្រូវបាន គេបង្រៀននៅក្នុងសាលាឬទេ ? បើមាន តើគេបង្រៀនរបៀបណា? តើលិទ្ធិប្រជាធិបតេយ្យ ការសិក្សាពីសន្តិភាពមានឥទ្ធិពលដល់សង្គមដែរឬទេ? តើគេអាចធ្វើការវាយតម្លៃបានឬទេ? ឬមុខវិជ្ជានេះគ្រាន់តែជាមុខវិជ្ជាបន្ទាប់បន្សំ ដែលឥទ្ធិពលរបស់វានឹងឆ្លុះបញ្ចាំងឲ្យឃើញក្នុងរយៈពេលយូរឆ្នាំក្រោយទៀតឬយ៉ាងណា ?

# ២.៨ ការអប់រំក្នុងសង្គម

## ២.៨.២. ចំណេះដឹងប្រពៃណី និងបុរាណ

យើងតែងគិតថាចំណេះដឹងគឺជាអ្វីដែលយើងទទួលបានពីសាលា ឬ សាកលវិទ្យាល័យ ឬជាអ្វីដែលយើងទទួលបានពីការ អានសៀវភៅ និងឯកសារផ្សេងៗទៀត ។ ប៉ុន្តែបទពិសោធន៍ ៥ ទសវត្សរ៍កន្លងមកនៅក្នុងការអភិវឌ្ឍន៍បានបង្ហាញប្រាប់យើងថា រាល់សហគមន៍ទាំងអស់សុទ្ធតែមានចំណេះដឹងអំពីអ្វីមួយដែលមិនអាចកាត់ថ្លៃបាន ដែលមានតម្លៃធំធេងចំពោះជីវភាពរស់នៅប្រចាំថ្ងៃ ។ "ចំណេះដឹង" នេះមិនអាចរៀនពីសាលាបានទេ ។ ពីមុនមកយើងមិនបានចាត់ទុកវាថាជា "ចំណេះដឹង"ទេ ពីព្រោះយើងធ្លាប់តែគិតថាចំណេះដឹងគឺអ្វីៗដែលយើងរៀនសូត្របានមកពីសាលា ។

ទ្រព្យសម្បត្តិសហគមន៍ដ៏មានតម្លៃនេះគឺជាអ្វីដែលគេហៅថា "ចំណេះដឹងដើម" ។ វាគឺជាអ្វីដែលកសិករ និងអ្នកនេសាទរៀននៅក្នុងជីវិតរបស់គេ ហើយបន្តពីជំនាន់មួយទៅជំនាន់មួយទៀត ។ ចំណេះដឹងបុរាណនេះធ្វើឲ្យកសិករយល់ដឹងពីអាកាសធាតុ គ្រប់គ្រងដីធ្លី ដោះស្រាយបញ្ហាសត្វល្អិតចង្រៃ សំរេចថាបន្លែអ្វីត្រូវដាំ និងដាំនៅពេលណា។ វាជាចំណេះដឹងដែលមាននៅក្នុងខ្លួនរបស់ប្រជាជនគ្រប់រូបដើម្បីទាញយកផលប្រយោជន៍ពីបរិយាកាសនៅជុំវិញខ្លួនដើម្បីបំរើតំរូវការ ។ វាក៏ដូចជាចំណេះដឹងដែលម្តាយ ឬ ជីដូនជីតាអ្នកប្រើប្រាស់ដើម្បីមើលថែរក្សាអ្នកកាលពីអ្នកនៅជាទារករហូតដល់អ្នកធំ ។

ចំណេះដឹងបុរាណគឺជាលទ្ធផលនៃការសិក្សាមួយជីវិត ។ វាត្រូវបានគេរៀនតាមរយៈការស្តាប់ដកបទពិសោធន៍ពីអ្នកដទៃ អង្កេតមើលសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនពិសោធន៍ជាមួយនឹងចំណេះដឹងថ្មីៗ និងការឆ្លុះបញ្ចាំងឡើងវិញពីបទពិសោធន៍ទាំងអស់នេះ ។

អ្នកសារព័ត៌មានអាចចូលរួមក្នុងការថែរក្សា និងលើកកំពស់ចំណេះដឹងបុរាណបែបនេះដោយពង្រីកដំណើរការទាំងអស់ខាងលើឲ្យកាន់តែទូលំទូលាយតាមរយៈការបោះពុម្ព ឬផ្សព្វផ្សាយក្នុងប្រព័ន្ធសារព័ត៌មាន ។

C·O·L

# ២.៨ ការអប់រំក្នុងសង្គម

## ២.៨.២. ចំណេះដឹងប្រពៃណី និងបុរាណ

ឧទាហរណ៏ : សំភៀសន៏ជាមួយកសិករ អ្នកនេសាទ សិប្បករ លោយាយ លោកតាចាស់ៗ គ្រូឱសថបុរាណ និងតន្ត្រីករដែលទទួលការគោរពស្រលាញ់ ដោយសារបញ្ញាញាណ និងជំនាញពិសេសរបស់គេមិនត្រឹមតែជួយចែករំលែកចំណេះដឹងប៉ុណ្ណោះទេ តែថែមទាំងលើការធ្វើឲ្យចំណេះដឹងរបស់គេកាន់តែមានមានសុពលភាព គឺកាន់តែមានអ្នកទទួលស្គាល់ និងរៀនតាមច្រើន។

សុពលភាពបែបនេះ ដោយបណ្តាញព័ត៌មាន មានសារៈសំខាន់ណាស់ពីព្រោះវាមានភស្តុតាងបញ្ជាក់ថា ប្រជាជនរស់នៅទាំងនៅជនបទ និងទីក្រុងកំពុងតែបាត់បង់ការយកចិត្តទុកដាក់ចំពោះចំណេះដឹងបុរាណបែបនេះ។



# ២.៨ ការអប់រំក្នុងសង្គម

## ២.៨.៣. វប្បធម៌

បេសកកម្មខាងត្បូង ក្រុមអ្នកដឹកនាំដែលមានសក្តានុភាព និងអ្នកសិក្សាស្រាវជ្រាវមកពីប្រទេសកំពុងអភិវឌ្ឍន៍សន្និដ្ឋានថា វប្បធម៌របស់ប្រជាជនគឺជាគន្លិះសំរាប់ការអភិវឌ្ឍន៍។ មូលដ្ឋានវប្បធម៌ដែលខ្លាំងក្លាមួយផ្តល់ឲ្យប្រជាជននូវមូលដ្ឋានគ្រិះដ៏រឹងមាំសំរាប់កសាងអនាគតដោយឈរលើមូលដ្ឋានវប្បធម៌នោះ ។

ចំណុចដ៏សំខាន់មួយក្នុងចំនោមចំណុចសំខាន់នានារបស់វប្បធម៌សហគមន៏គឺប្រព័ន្ធផ្សព្វផ្សាយសហគមន៍។ សហគមន៏បង្ហាញពីអត្តសញ្ញាណវប្បធម៌របស់ខ្លួនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។ប្រព័ន្ធផ្សព្វផ្សាយ "ល្អ" គឺជាកញ្ចក់ឆ្លុះបញ្ចាំង សង្គមដ៏ល្អ ។ ប៉ុន្តែអំណាចរបស់ប្រព័ន្ធផ្សព្វផ្សាយនៅសម័យនេះអាចផ្លាស់ប្តូរមុខមាត់សង្គមបាន ។ អ្នកសារព័ត៌មាន អាចប្រើប្រាស់អំណាចនេះឲ្យមានលទ្ធផលខុស ៗគ្នា ។ ក្នុងករណីតន្ត្រីប្រជាប្រិយ បណ្តាញផ្សព្វផ្សាយបានទទួល ជោគជ័យក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ក្មេង ៗនៅក្នុងប្រទេសជាច្រើន ។ អ្នកអង្កេតការមួយចំនួនបានសួរថាថាតើការយល់ឃើញពីខ្លួនរបស់គេថ្មីនេះ បាននាំមកនូវតម្លៃវប្បធម៌ថ្មីសំរាប់ខ្លួនគេឬយ៉ាងណា ។

គុណធម៌ស្ថិតនៅលើបេះដូងរបស់អ្នករៀបចំកម្មវិធីអប់រំភាគច្រើន ។ គុណធម៌របស់អ្នករៀនផ្តល់ទិសដៅដល់ព័ត៌មាន និងបច្ចេកវិទ្យា "មិនលំអៀង" ដែលគាត់អាចទទួលយកបានតាមរយៈការសិក្សាគ្រប់ប្រភេទ ។ អ្នកសិក្សានឹងត្រូវធ្វើការសំរេចចិត្តចុងក្រោយសំរាប់ខ្លួនគេនូវគុណធម៌ដែលគេត្រូវជ្រើសរើសយក និងវប្បធម៌មួយណាគេត្រូវប្រតិបត្តិតាម ។ សារព័ត៌មានអាចជួយឲ្យគេធ្វើការសំរេចចិត្ត ដោយបង្ហាញនូវការពិភាក្សាចម្រុះបង្ហាញដល់បញ្ហាពាក់ព័ន្ធ ។

ដោយធ្វើបែបនេះ អ្នកនឹងអាចជួយជំរុញវប្បធម៌មួយសំរាប់ឆ្លុះបញ្ចាំង និងពិភាក្សាវែកញែកដ៏ស៊ីជំរៅផងដែរ ។ នេះគឺជាអ្វីដែលគេតែងតែភ្លេចក្នុងការអភិវឌ្ឍន៏សហគមន៏ និងការអប់រំមួយជីវិត ព្រមទាំងអប់រំចំណេះទូទៅក្នុងប្រព័ន្ធ។

C·O·L

section 2.8.qxp 21/12/2004 8:22 AM Page 7



# ២.៨ ការអប់រំក្នុងសង្គម

## ២.៨.៤. គំនិតតាមរយៈសាច់រឿងមូលដ្ឋាន

១. ការជំរុញលិទ្ធិប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្សពុំមែនជាការទទួលខុសត្រូវរបស់គ្រូ និងសិស្សប៉ុណ្ណោះទេ ប៉ុន្តែ តើសហគមន៍ ជាពិសេស អ្នកនយោបាយ សង្គមស៊ីវិល ។ល។ ក៏ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអ្នកអប់រំដើម្បីផ្សព្វផ្សាយអំពីលិទ្ធិប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្ស? តើមានឧទាហរណ៍ជាក់ស្តែងឬទេនៅក្នុងសហគមន៍របស់អ្នកដែលសាលាបានចាប់ផ្តើមរៀបចំគោលគំនិតធំ និងធ្វើផែនការដើម្បីបង្រៀនមេរៀនអំពីលិទ្ធិប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្សនៅក្នុងសាលារៀន? បើអ្នកផ្សេងទៀតដែលមិនមែនជាអ្នកអប់រំបានចូលរួមលើកទឹកចិត្តសិស្សឲ្យរៀនលិទ្ធិប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិមនុស្សឬទេ? បើមានតើមានលទ្ធផលអ្វីខ្លះហើយ? ក្នុងនាមជាអ្នកសារព័ត៌មាន តើអ្នកអាចរកព័ត៌មានល្អៗដើម្បីសរសេរពីបញ្ហានេះបានដោយរបៀបណា?

២. រឿងអំពីចំណេះដឹងបុរាណ និងប្រជាជនដែលមានចំណេះដឹងបែបនេះគឺជាខ្លឹមសារព័ត៌មានដ៏ល្អសំរាប់សារព័ត៌មាន ។ បញ្ហានេះជាខ្លឹមសារដែលមានផលប្រយោជន៍ដល់ការរៀនសូត្រមួយជីវិតរបស់មនុស្សគ្រប់រូប ។

៣. ក្នុងផ្នែកវប្បធម៌ និង អប់រំ ពិចារណារព័ត៌មានមួយចំនួនពីបរិយាកាសជុំវិញខ្លួនអ្នក ។ សរសេរខ្លះបញ្ជាំងពីការបញ្ចូលតម្លៃវប្បធម៌នេះទៅក្នុងកម្មវិធីសិក្សានៅក្នុងសាលានៅក្នុងប្រទេសរបស់អ្នក ។